# សាររបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# ជូនជនរួមជាតិ
# ស្តីពីវិធានការរបស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងផលប៉ះពាល់ ពីជំងឺរលាកសួតផ្លូវដង្ហើមធ្ងន់ធ្ងរ (ខូវិដ-១៩) និង ការព្យួរតារាងអនុគ្រោះពន្ធលើ ទំនិញមួយចំនួន ក្រោមកម្មវិធី «ទំនិញគ្រប់មុខ លើកលែងអាវុធ» (EBA)

****+****

- ***សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***
- ***ជនរួមជាតិ ជាទីគោរពស្រឡាញ់ !***

នៅក្នុងពេលថ្មីៗនេះ, ជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរដែលបណ្តាលមកពីមេរោគខូវីដ-១៩ (COVID-19) បានក្លាយទៅជាបញ្ហាប្រឈមដ៏ធំមួយទៀត ក្នុងចំណោមបញ្ហាប្រឈមមានស្រាប់នានា សម្រាប់សកលលោក ពិសេសគឺសង្គ្រាមពាណិជ្ជកម្ម និង ការថមថយនៃកំណើនសេដ្ឋកិច្ច ។ ផលប៉ះពាល់ពីជម្ងឺខូវីដ-១៩ បានមកដល់លឿន, មិនអាចព្យាករទុកជាមុនបានអំពីទំហំរបស់វា ហើយកំពុងបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចនៅក្នុងប្រទេសនានានៅតំបន់អាស៊ី និង អាចរុញច្រានសេដ្ឋកិច្ចនៃប្រទេសមួយចំនួន ឲ្យធ្លាក់ទៅក្នុងវិបត្តិ ។ ប្រការនេះ ក៏បានបង្កើតជាការព្រួយបារម្ភ និង ភាពរំជើបរំជួល ដល់វិនិយោគិន, និយោជិត និង សាធារណជនផងដែរ ។ រដ្ឋាភិបាលនៃប្រទេសជាច្រើននៅក្នុងតំបន់ បានប្រញាប់ប្រញាល់ដាក់ចេញនូវវិធានការ ដើម្បីជួយស្រោចស្រង់, កាត់បន្ថយនូវផលប៉ះពាល់ និង គាំទ្រលើកស្ទួយនូវកំណើនសេដ្ឋកិច្ច ។ ដូចប្រទេសដទៃទៀតនៅក្នុងតំបន់, ជម្ងឺខូវីដ-១៩ នេះ ក៏មានផលប៉ះពាល់មកលើវិស័យសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជាដែរ ដែលក្នុងនោះ, តាមការវាយតម្លៃបឋម, មានវិស័យពីររងផលប៉ះពាល់ធ្ងន់ជាងគេ គឺ៖ (ទី១)-វិស័យទេសចរណ៍ ដោយមូលហេតុ អ្នកទេសចរមានការភ័យខ្លាចលែងហ៊ានធ្វើដំណើរកំសាន្ត និង ការបិទជើងយន្ត-ហោះ, និង (ទី២)-វិស័យកាត់ដេរ ដោយសារការខ្វះវត្ថុធាតុដើម ត្បិតរោងចក្រមួយចំនួននៅប្រទេសចិនមិនទាន់បើកដំណើការឡើងវិញជាប្រក្រតី ។

នៅក្នុងបរិការណ៍នេះ, រាជរដ្ឋាភិបាលក៏មិនឱបដៃនៅស្ងៀមមើលសហគ្រាស និង ក្រុមហ៊ុន ទទួលរងនូវផលប៉ះពាល់, ក្ដួយៗជាកម្មករ-និយជិតមួយចំនួន បាត់បង់ការងារ, ហើយកំណើនសេដ្ឋកិច្ចថមថយធ្លាក់ចុះ ដែលអាចបង្កជាហានិភ័យដល់សង្គមជាតិទាំងមូល នោះឡើយ ។ អាស្រ័យហេតុនេះ, ក្នុងស្មារតីបុរេសកម្ម, ថ្ងៃនេះ, រាជរដ្ឋាភិបាលបានសម្រេចចិត្តដាក់ចេញនូវវិធានអន្តរាគមន៍បន្ទាន់ ដើម្បីគ្រប់គ្រងផលប៉ះពាល់ចំពោះមុខ នៅក្នុងវិស័យមួយចំនួន ក្នុងគោលដៅធានាលំនឹងនៃសេដ្ឋកិច្ច និង សង្គម ។ ក្នុងការដាក់ចេញវិធានការទាំងអស់នេះ, រាជរដ្ឋាភិបាលបានគិតគូរលើគ្រប់ទិដ្ឋភាព សំដៅជួយដល់គ្រប់តួអង្គពាក់ព័ន្ធផង និង ជំរុញលើកស្ទួយកំណើននៅតាមវិស័យដែលមានសល់សក្តានុពលផង រួមមាន៖ (ទី១)-ជួយដល់ក្រុមហ៊ុន

ដែលទទួលរងផលប៉ះពាល់ខ្លាំង ដើម្បីឲ្យក្រុមហ៊ុនទាំងនោះ អាចបន្តអាជីវកម្មបាននៅក្នុងពេលដ៏លំបាកនេះ; (ទី២)-ជួយដល់កម្មករ-និយោជិត, ក្នុងករណីត្រូវបាត់បង់ ឬ ត្រូវព្យួរការងារ, ឱ្យមានលំនឹងជីវភាព និង អាចលើកកម្ពស់ជំនាញ ព្រមទាំងផលិតភាពការងាររបស់ខ្លួនសម្រាប់អនាគត; និង (ទី៣)-ជួយទ្រទ្រង់លើកស្ទួយកំណើន ជាពិសេស ជួយដល់សហគ្រាសធុនតូច និង មធ្យម ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ។ ទន្ទឹមនេះ, វិធានការដែលត្រូវបានដាក់ចេញមកនេះ មិនត្រឹមតែជួយកាត់បន្ថយផលប៉ះពាល់ចំពោះមុខប៉ុណ្ណោះទេ តែក៏ជាវិធានការជួយលើកស្ទួយភាពប្រកួតប្រជែងដល់វិស័យទាំងនោះ និង សេដ្ឋកិច្ចជាតិទាំងមូល នៅពេលជំងឺខូវីដ-១៩ បានឆ្លងផុតទៅ ផងដែរ ។

មុននឹងជម្រាបអំពីវិធានការនានា, ខ្ញុំសូមយកឱកាសនេះបញ្ជាក់សាជាថ្មីថា ជំងឺខូវីដ-១៩ និង បញ្ហាប្រឈមផ្សេងៗទៀត មិនបង្កជាផលប៉ះពាល់ធ្ងន់ធ្ងរ និង ហួសហេតុ ដល់សេដ្ឋកិច្ចកម្ពុជានោះទេ ។ អ្វីដែលអាចបង្កហានិភ័យធំមកលើសេដ្ឋកិច្ច និង សង្គមកម្ពុជា គឺៈ **«ជំងឺភ័យខ្លាច»** ដោយខ្វះហេតុផល ឬ ការស្លន់ស្លោ ដោយសារការបន្លាច ឬ ការឃោសនាអកុសលរបស់ក្រុមជនអគតិមួយចំនួន ដែលមានបំណងបង្កភាពចលាចលនៅក្នុងសង្គមជាតិដើម្បីផលប្រយោជន៍របស់ខ្លួនតែប៉ុណ្ណោះ ។ ជាការពិត, មូលដ្ឋានសេដ្ឋកិច្ចកម្ពុជា នៅបន្តមានភាពរឹងមាំ ។ ដូច្នេះ, ខ្ញុំស្នើសុំឱ្យវិនិយោគិន, ទាំងជនជាតិកម្ពុជា និង បរទេស, មានជំនឿទុកចិត្តលើរាជរដ្ឋាភិបាល និង ចូលរួមអនុវត្តនូវវិធានការទាំងអស់ យ៉ាងសកម្ម ។ ចំពោះក្មួយៗជាកម្មករ-និយោជិតទាំងអស់, រាជរដ្ឋាភិបាលនឹងធានារកការងារជូន ប្រសិនបើជួបប្រទះនឹងបញ្ហាបាត់បង់ការងារ ។ ក្នុងករណីដែលក្មួយៗមិនទាន់ចង់ធ្វើការងារ ហើយចង់ស្វែងរកឱកាសក្នុងការបង្កើនសមត្ថភាពជំនាញរបស់ខ្លួន, ក្មួយៗ អាចចូលរួម និង ទទួលការបណ្តុះបណ្តាល ដែលរៀបចំដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាមួយនឹងប្រាក់បំណាច់ក្នុងកម្រិតមួយសមរម្យ ។

ទន្ទឹមនេះ, ខ្ញុំក៏សូមជម្រាបថែមទៀតថា អ្វីដែលបានដាក់ចេញនាពេលនេះ គឺជាកញ្ចប់វិធានការជុំទីមួយ ដើម្បីកាត់បន្ថយផលប៉ះពាល់, រក្សាលំនឹងអាជីវកម្ម និង លំនឹងជីវភាពជូនក្មួយៗកម្មករ-និយោជិតទាំងអស់ ។ រាជរដ្ឋាភិបាលនឹងបន្តតាមដានស្ថានភាពសេដ្ឋកិច្ចជាប្រចាំ ។ ក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរងផលប៉ះពាល់កាន់តែធ្ងន់ធ្ងរ, រាជរដ្ឋាភិបាលអាចបន្តអនុវត្តនូវវិធានការទាំងនេះ និង ដាក់ចេញនូវវិធានថ្មីៗបន្ថែមទៀត តាមការចាំបាច់ ។

ជាការពិត, វិធានការដែលរាជរដ្ឋាភិបាលបានរៀបចំដាក់ចេញមកនេះ មានច្រើន និង មានលក្ខណៈប្រទាក់ក្រឡាគ្នា ជាអន្តរវិស័យ និង អន្តរក្រសួង-ស្ថាប័ន ។ នៅពេលនេះ, ខ្ញុំសូមអនុញ្ញាតជម្រាបជូនតែវិធានការណា ដែលទាក់ទងផ្ទាល់ជាមួយវិស័យឯកជន និង ក្មួយៗកម្មករ-និយោជិតប៉ុណ្ណោះ ។ ចំណែកវិធានការផ្សេងទៀត ដែលទាក់ទងទៅនឹងស្ថាប័នរដ្ឋ និង បានទទួលការឯកភាពពីខ្ញុំរួចហើយ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** នឹងយកទៅចាត់ចែងបន្តជាមួយស្ថាប័ន និង តួអង្គពាក់ព័ន្ធតែម្តង ដើម្បីជំរុញអនុវត្តឲ្យទាន់ពេល និង មានប្រសិទ្ធភាព ក្នុងស្មារតីសាមគ្គីភាព, កិច្ចសហការ និង ការទទួលខុសត្រូវខ្ពស់ ។

តទៅនេះ, ខ្ញុំសូមជម្រាបជូនអំពីវិធានការទាំងឡាយ ដូចខាងក្រោមៈ

## ១. វិធានការជួយគាំទ្រដល់វិស័យទេសចរណ៍

ជាមួយនឹងការភ័យខ្លាចជំងឺកូវីដ-១៩, វិស័យទេសចរណ៍នៅក្នុងតំបន់ និង ប្រទេសកម្ពុជា ទទួលរងនូវផលប៉ះពាល់គួរឲ្យកត់សម្គាល់ ។ នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០២០, ភ្ញៀវទេសចរណ៍បរទេសចូលមកកម្ពុជាបានធ្លាក់ចុះប្រមាណជាង ៦០%, ជាពិសេស ភ្ញៀវទេសចរជនជាតិចិន បានធ្លាក់ចុះក្នុងរង្វង់ ៩០% ។ បើធៀបជាមួយនឹងគោលដៅទេសចរណ៍សំខាន់នៅក្នុងប្រទេស, អាជីវកម្មទេសចរណ៍នៅខេត្តសៀមរាប ទទួលរងនូវផលប៉ះពាល់ជាខ្លាំង ។ សកម្មភាពទេចរណ៍នៅតំបន់ដ៏ទៃទៀត ស្ថិតនៅក្នុងកម្រិតសមរម្យ ។ ជាមួយនឹងហេតុផលនេះ, វិធានការដែលរាជរដ្ឋាភិបាលបានដាក់ចេញ ក្នុងដំណាក់កាលនេះ គឺផ្តោតទៅលើការជួយដល់អាជីវកម្មទេសចរណ៍ ក៏ដូចជាជំរុញសកម្មភាពទេសចរណ៍នៅខេត្តសៀមរាប ។ គោលគំនិតធំៗនៃការដាក់វិធានការ គឺសំដៅជួយឲ្យសណ្ឋាគារ និង ផ្ទះសំណាក់ អាចបន្តអាជីវកម្មរបស់ខ្លួនបាន, រក្សាបាននូវការងារជូនក្មួយៗកម្មករ-និយោជិត និង មានភាពប្រកួតប្រជែងខ្លាំងជាងមុន នៅពេលជំងឺកូវីដ-១៩នេះ កន្លងផុតទៅ ។ ទន្ទឹមនេះដែរ, វិធានការមួយចំនួនទៀត ក៏នឹងជួយដល់ក្មួយៗដែលបាត់បង់ការងារពីវិស័យទេសចរណ៍ តាមរយៈការរៀបចំនូវការបណ្តុះបណ្តាល ដើម្បីមានឱកាសចាប់យកជំនាញថ្មី ឬ មានលទ្ធភាពទទួលបានការងារល្អប្រសើរជាងមុន ។

ជាមួយគោលដៅខាងលើ, រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសម្រាប់ជួយគាំទ្រវិស័យទេសចរណ៍ដូចខាងក្រោម៖

- ទី១. លើកលែង(រដ្ឋទទួលបន្ទុកពន្ធជំនួស) នូវការបង់ពន្ធប្រចាំខែគ្រប់ប្រភេទរបស់សណ្ឋាគារ និង ផ្ទះសំណាក់ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និង មានសកម្មភាពអាជីវកម្មក្នុងខេត្តសៀមរាប សម្រាប់រយៈពេលបួនខែ ដោយគិតចាប់ពីខែ កុម្ភៈ រហូតដល់ខែ ឧសភា ឆ្នាំ ២០២០ ។ អាជីវកម្មសណ្ឋាគារ និង ផ្ទះសំណាក់ នៅតែមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធអាករ និង ប្រើប្រាស់ប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែម (E-VAT) ជារៀងរាល់ខែ ក្នុងរយៈពេលលើកលែងពន្ធនេះ;
- ទី២. មិនធ្វើសវនកម្មពេញលេញ សម្រាប់ការិយបរិច្ឆេទឆ្នាំ ២០២០ ចំពោះសហគ្រាសក្នុងវិស័យសណ្ឋាគារ និង ផ្ទះសំណាក់ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និង មានសកម្មភាពអាជីវកម្មក្នុងខេត្តសៀមរាប;
- ទី៣. ធ្វើវិចារណកម្មថវិកាជាតិឆ្នាំ ២០២០, ទាំងចំណាយចរន្ត និង ចំណាយវិនិយោគ, ពិសេសកាត់បន្ថយការធ្វើដំណើរចូលរួមក្នុងកិច្ចប្រជុំនៅក្រៅប្រទេស ដោយគ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និង ចូលរួមជំរុញវិស័យទេសចរណ៍ក្នុងស្រុក ឲ្យទៅជាចលនាជាតិធំទូលាយ តាមរយៈ ការជំរុញនូវការធ្វើសិក្ខាសាលា, កិច្ចប្រជុំ, វគ្គបណ្តុះបណ្តាលខ្លីៗ និង កម្មវិធីផ្សេងៗទៀត រៀបចំដោយគ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល, វិស័យឯកជន, ស្ថានទូត, អង្គការមិនមែនរដ្ឋាភិបាល ឲ្យទៅធ្វើនៅតាមខេត្តសំខាន់ៗ ពិសេសគឺខេត្តសៀមរាប;

ទី៤. បង្កើនប្រសិទ្ធភាពនៃការធ្វើដំណើររួមគ្នាតាមផ្លូវគោក, ផ្លូវទឹក និង ផ្លូវអាកាស ជាពិសេស ជាមួយប្រទេសជិតខាង (ដូចជា បាងកក-សៀមរាប និង ហូជីមិញ-សៀមរាប) ពិសេស តាមរយៈរថយន្តក្រុង ឬ រថយន្តផ្ទាល់-ខ្លួន ដោយធ្វើការសម្របសម្រួលដោះស្រាយប្រកបដោយប្រសិទ្ធភាព នូវបញ្ហាប្រឈមនានាដែលកើតមានឡើងនៅកន្លែងទទួលសេវាកម្មឆ្លងកាត់ព្រំដែន និង បញ្ហាពាក់ព័ន្ធដទៃទៀត;

ទី៥. ក្រសួងទេសចរណ៍ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវបើកយុទ្ធនាការរៀបចំសកម្មភាព និង ព្រឹត្តិការណ៍ទាក់ទាញផ្សេងៗនៅក្នុងខេត្តសៀមរាប ដូចជា អង្គរសង្ក្រាន (២០២០), ពិធីបុណ្យប្រពៃណី-សាសនា, កម្មវិធីប្រកួតកីឡា, ការប្រគុំតន្ត្រី, ការបញ្ចាំងភាពយន្ត និង ការបង្ហាញម៉ូដសំលៀកបំពាក់ ជាដើម សម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និង អន្តរជាតិ;

ទី៦. រក្សាថ្លៃសំបុត្រចូលទស្សនាតំបន់អង្គរឱ្យនៅដដែល ប៉ុន្តែបន្ថែមចំនួនថ្ងៃសម្រាប់ប្រភេទសំបុត្រនីមួយៗ, សំបុត្រសម្រាប់ ១ ថ្ងៃអាចចូលមើលបាន ២ ថ្ងៃ, សំបុត្រសម្រាប់ ៣ ថ្ងៃ អាចចូលមើលបាន ៥ ថ្ងៃ និង សំបុត្រសម្រាប់ ៧ ថ្ងៃ អាចចូលមើលបាន ១០ ថ្ងៃ ដើម្បីទាក់ទាញទេសចរឲ្យស្នាក់នៅបន្ថែម នៅក្នុងព្រះរាជាណាចក្រកម្ពុជា;

ទី៧. ក្រសួងទេសចរណ៍ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលដល់កម្មករ-និយោជិត ដែលបាត់បង់ការងារនៅក្នុងវិស័យទេសចរណ៍ (បុគ្គលិកបម្រើការនៅតាមសណ្ឋាគារ, ផ្ទះសំណាក់, និង ភ្នាក់ងារទេសចរណ៍) តាមរយៈការរៀបចំឱ្យមាននូវវគ្គបណ្តុះបណ្តាលនៃមុខវិជ្ជាចំណេះដឹងថ្មី (Re-skilling) ឬ ការបង្កើនចំណេះដឹងបន្ថែម (Upskilling) និង ការផ្តល់នូវប្រាក់ខែសមរម្យ ។

## ២. វិធានការជួយវិស័យកាត់ដេរសំលៀកបំពាក់, ស្បែកជើង និងការបូប

វិស័យកាត់ដេរក៏ទទួលនូវផលប៉ះពាល់ច្រើនពីការភ័យខ្លាចជំងឺខូវីដ-១៩ នេះផងដែរ ដោយសាររោងចក្រនៅប្រទេសចិនភាគច្រើនមិនទាន់បើកដំណើរការពេញលេញនៅឡើយ ដែលធ្វើឱ្យការផ្គត់ផ្គង់ទៅកាន់ទីផ្សារផ្សេងទៀត រួមទាំង ប្រទេសកម្ពុជាផង មានភាពយឺតយ៉ាវ ហើយប្រឈមនឹងការខ្វះវត្ថុធាតុដើមសម្រាប់ការផលិត ។ មកដល់ពេលនេះ, មានរោងចក្រមួយចំនួនតូចបានចាប់ផ្តើមគិតគូរពីការព្យួរសកម្មភាពផលិតកម្ម សម្រាប់រយៈពេលខ្លី ។ ទន្ទឹមនេះ, ការព្យួរភាពអនុគ្រោះពន្ធលើទំនិញមួយចំនួន នៅក្រោមកម្មវិធី EBA ក៏នឹងបង្កផលប៉ះពាល់ខ្លះទៅលើការផលិតរបស់រោងចក្រមួយចំនួនតូចដែរ ។ ហេតុនេះ, ដូចវិស័យទេសចរណ៍ដែរ, រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការមួយចំនួនសម្រាប់ជួយគាំទ្រដល់វិស័យនេះ ដែលជាគោលការណ៍វិធានការទាំងនោះ ត្រូវបានរៀបចំសំដៅជួយទាំងរោងចក្រ-សហគ្រាស និង កម្មករ-និយោជិត ដែលទទួលផលប៉ះពាល់, ទាំងពីជំងឺខូវីដ-១៩ និង ទាំងពីការព្យួរ EBA ។

ជាមួយគោលដៅខាងលើ, ខ្ញុំសូមជម្រាបជូននូវបណ្តាវិធានការសម្រាប់ជួយដល់រោងចក្រ-សហគ្រាស ដែលទទួលរងផលប៉ះពាល់ពីការខ្វះវត្ថុធាតុដើម និង ពីការព្យួរ EBA ដូចខាងក្រោម៖

ទី១. ពិនិត្យផ្តល់ជូនការលើកលែងពន្ធ (Tax holiday) អាចពី ៦ ខែ ទៅ ១ ឆ្នាំ សម្រាប់រោងចក្រ-សហគ្រាស ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ទៅតាមកម្រិតភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ជាក់-

ស្តែងលើរោងចក្រនីមួយៗ ដែលបណ្តាលមកពីការខ្វះវត្ថុធាតុដើមផលិត ឬ/និង ការព្យួរ EBA (ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវដឹកនាំសម្របសម្រួលរៀបចំរូបមន្ត និង គោលការណ៍ជាក់លាក់ សម្រាប់ការវាយតម្លៃផ្តល់ការលើកលែងពន្ធនេះ);

ទី២. អនុញ្ញាតឱ្យរោងចក្រមិនបង់ប្រាក់ភាគទានធានារ៉ាប់រងរបបហានិភ័យការងារ និង ថែទាំសុខភាព (បសស) ក្នុងអំឡុងពេលរោងចក្រព្យួរអាជីវកម្ម;

ទី៣. សម្រាប់រោងចក្រ-សហគ្រាស ដែលផ្អាកសកម្មភាពផលិតរយៈពេលខ្លី ដោយសារខ្វះវត្ថុធាតុដើម, រោងចក្រ-សហគ្រាសត្រូវចេញប្រាក់ខែចំនួន ៤០% នៃប្រាក់ខែអប្បរមារបស់កម្មករ-និយោជិត (ដែលមានចំនួន ១៩០ ដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០២០) ខណៈរាជរដ្ឋាភិបាលនឹងចូលរួមចំណែក ២០% នៃប្រាក់ខែអប្បរមាបន្ថែម (សរុប ៦០% នៃប្រាក់ខែអប្បរមា) ។ ដើម្បីបានទទួលនូវការឧបត្ថមនេះ ក្មួយៗជាកម្មក-និយោជិតត្រូវចូលរួមវគ្គបណ្តុះបណ្តាលខ្លីៗ រវាងពី ១ ទៅ ២ សប្តាហ៍ ដែលរៀបចំដោយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ នៅតាមបណ្តារោងចក្រ-សហគ្រាស;

ទី៤. ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវសហការជាមួយសមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC) និង ដៃគូពាក់ព័ន្ធ ដើម្បីជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីលទ្ធផលការងាររបស់ «**គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (Better Factories Cambodia-BFC)**» ដើម្បីឱ្យអ្នកបញ្ជាទិញបានដឹងថា ទំនិញពីកម្ពុជាមានការគោរពនូវសិទ្ធិមនុស្ស, សិទ្ធិការងារ, មានលក្ខខណ្ឌការងារល្អប្រសើរ និង មិនមានការប្រើប្រាស់ពលកម្មកុមារ ។

សម្រាប់វិធានការជួយដល់ក្មួយៗជាកម្មករ-និយោជិត ដែលបាត់បង់ការងារ និង មិនទាន់អាចរកការងារថ្មីបាន ឬ ចង់ផ្លាស់ប្តូរការងារនាពេលអនាគត, ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលជូនដល់ក្មួយៗ ដែលរួមមានដូចខាងក្រោម៖

ទី១. ផ្តល់សេវាជួយរកការងារឲ្យកម្មករធ្វើ តាមរយៈទីភ្នាក់ងារជាតិមុខរបរ (NEA) ដែលអាចជួយជំរុញកម្មករ-និយោជិត ដែលបាត់បង់ការងារឱ្យចាប់យកការងារថ្មីបានឆាប់រហ័ស;

ទី២. បណ្តុះបណ្តាលជំនាញទន់ (Soft skills) រយៈពេលខ្លីពី ១ ដល់ ២ សប្តាហ៍ ដល់កម្មករ-និយោជិត ដែលបាត់បង់ការងារ និង មិនទាន់រកការងារធ្វើឡើងវិញបាន;

ទី៣. បណ្តុះបណ្តាលជំនាញបច្ចេកទេសរយៈពេល ៤ ខែ ដើម្បីបំពាក់ជំនាញថ្មី និង ផ្តល់ភាពងាយស្រួល ក្នុងការរកការងារធ្វើ ក្នុងវិស័យមិនមែនកាត់ដេរ;

ទី៤. ផ្តល់ជូនដល់សិក្ខាកាម ដែលត្រូវបានជ្រើសរើស និង ទទួលបានការបណ្តុះបណ្តាល នូវប្រាក់ឧបត្ថម្ភ ចំនួន ១២០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់រយៈពេល ៦ ខែ (៤ ខែសម្រាប់ការបណ្តុះបណ្តាល និង ២ ខែសម្រាប់ទុកបម្រុងក្នុងអំឡុងពេលរកការងារធ្វើមិនទាន់បាន) ។

## ៣. វិធានការទ្រទ្រង់កំណើន

បន្ថែមពីវិធានការរយៈពេលខ្លី ដែលបានដាក់ចេញសម្រាប់ជួយដល់វិស័យទេសចរណ៍, វិស័យកាត់ដេរ និង វិធានការជួយដល់កម្មករ-និយោជិត, រាជរដ្ឋាភិបាលក៏បានគិតគូរអំពីការទ្រទ្រង់កំណើន ក្នុងទម្រង់ជាការលើកទឹកចិត្តដល់វិស័យដែលនៅមានសក្តានុពលសម្រាប់ការរីកចម្រើន ជាអាទិ៍ សហគ្រាសធុនតូច និងមធ្យម ព្រមទាំងការជំរុញសកម្មភាពអាជីវកម្មនៅក្នុងវិស័យផ្សេងទៀត ពិសេស វិស័យសំណង់ និង អចលនទ្រព្យ ។ រាជរដ្ឋាភិបាលមានគោលបំណងប្រែក្លាយសហគ្រាសធុនតូច និង មធ្យម ឱ្យទៅជាកម្លាំងចលករជំរុញកំណើនសេដ្ឋកិច្ច, ផ្តល់ការងារកាន់តែច្រើនដល់ពលករកម្ពុជា និង មានលទ្ធភាពផលិតនូវទំនិញកាន់តែច្រើនជំនួសឱ្យការនាំចូល ។ ក្នុងគោលដៅនេះ, រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

ទី១. **រៀបចំបង្កើតគណៈកម្មាធិការសកម្មភាពគោលនយោបាយ ដើម្បីជំរុញ និង អភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម ដែលមានសមាជិកមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗ នៅក្រោមការដឹកនាំផ្ទាល់របស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** ។ គណៈកម្មាធិការនេះ នឹងដាក់ចេញនូវវិធានការដាក់ស្តែងពាក់ព័ន្ធនឹងការជំរុញ និង អភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម, តាមដានការអនុវត្ត និង ស្នើដាក់ចេញនូវវិធានការកែសម្រួល តាមការចាំបាច់;

ទី២. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវជំរុញការដាក់ឲ្យដំណើរការធនាគារសហគ្រាសធុនតូច និង មធ្យម (SME Bank) ឱ្យបានឆាប់;

ទី៣. រៀបចំដាក់កម្មវិធីហិរញ្ញប្បទានពិសេស ដែលមានទឹកប្រាក់រហូតដល់ ៥០ លានដុល្លារអាមេរិក តាមរយៈធនាគារអភិវឌ្ឍជនបទ (RDB) ដើម្បីផ្តល់កម្ចីមានការប្រាក់ទាប ដល់សហគ្រាសធុនតូច និង មធ្យម ក្នុងវិស័យកែច្នៃផលិតផលកសិកម្ម, វិស័យកសិ-ឧស្សាហកម្ម និង វិស័យកសិកម្ម ដែលមានដូចជា ការដាំបន្លែ, ការចញ្ចឹមសត្វ និង ការចញ្ចឹមត្រី ដើម្បីអនុញ្ញាតឱ្យសហគ្រាសធុនតូច និង មធ្យមទាំងនោះ មានលទ្ធភាពពង្រីក និង ធ្វើឱ្យប្រសើរឡើង នូវខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន ក្នុងគោលដៅបង្កើតការងារបន្ថែម និង ពង្រឹងភាពប្រកួតប្រជែង;

ទី៤. រៀបចំយន្តការចូលរួមធ្វើសហហិរញ្ញប្បទាន (Co-financing) និង ចែករំលែកហានិភ័យ (Risk sharing) ដែលមានទឹកប្រាក់រហូតដល់ ៥០ លានដុល្លារអាមេរិក តាមរយៈធនាគារសហគ្រាសធុនតូច និង មធ្យម (SME Bank) ដែលមានដើមទុនរួចហើយ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ធនាគារពាណិជ្ជនានា សំដៅជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម ក្នុងផ្នែកកម្មន្តសាល និង សិប្បកម្ម សម្រាប់ជំនួសឱ្យការនាំចូល, បម្រើសេចក្តីត្រូវការក្នុងស្រុក ឬ ផ្តល់ជាធាតុចូលនៅក្នុងការផលិតរបស់ក្រុមហ៊ុនធំៗ ។ យន្តការនេះ នឹងមានរយៈពេលមួយឆ្នាំ ហើយនឹងផ្តល់នូវឥណទានក្នុងអត្រាការប្រាក់ទាប ដល់សហគ្រាសធុនតូច និងមធ្យម;

ទី៥. **លើកលែងពន្ធប្រថាប់ត្រាសម្រាប់អ្នកទិញផ្ទះ ដែលមានថ្លៃទាបជាងប្រាំពីរម៉ឺនដុល្លារអាមេរិក ក្នុងរយៈពេល ១ ឆ្នាំ** ដោយគិតចាប់ពីខែ កុម្ភៈ ឆ្នាំ ២០២០ ដល់ខែ មករា ឆ្នាំ ២០២១ សម្រាប់

ក្រុមហ៊ុនអភិវឌ្ឍលំនៅដ្ឋាន ដែលបានចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងនៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏សូមអំពាវនាវដល់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅដ្ឋានទាំងអស់ ឲ្យចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការបញ្ចុះថ្លៃផ្ទះ ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

- ***សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***
- ***ជនរួមជាតិ ជាទីគោរពស្រឡាញ់ !***

អ្វីដែលខ្ញុំបានរៀបរាប់ពីខាងលើនេះ គឺជាវិធានការរយៈពេលខ្លី និង បន្ទាន់ សំដៅជួយដល់វិស័យសំខាន់ៗនៃសេដ្ឋកិច្ចជាតិ និង កម្មករ-និយោជិត ដែលរងផលប៉ះពាល់ នៅក្នុងសភាពការណ៍មិនអំណោយផលចំពោះមុខ ។ ដូចបានជម្រាបជូនខាងលើ, នេះ គឺជាកញ្ចប់នៃវិធានការជុំទីមួយ ។ ក្នុងករណីចាំបាច់, រាជរដ្ឋាភិបាលនឹងដាក់ចេញនូវវិធានការបន្ថែមទៀត ស្របទៅតាមការវិវត្តនៃសភាពការណ៍ជាក់ស្តែង ។ ទន្ទឹមនេះ, ខ្ញុំក៏បានណែនាំឱ្យគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំស្នើឡើងនូវវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ថ្មីបន្ថែមទៀត សម្រាប់ខ្ញុំពិចារណា និង ពិនិត្យសម្រេចដាក់ឲ្យអនុវត្ត ដែលខ្ញុំគ្រោងនឹងប្រកាសនៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩ នាថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០២០ ខាងមុខនេះ ដោយរាប់បញ្ចូលនូវ វិធានការបន្ថែមសម្រាប់ដោះស្រាយ និង កាត់បន្ថយផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងករណីចាំបាច់; វិធានការកែលម្អភាពប្រកួតប្រជែងរបស់កម្ពុជាសម្រាប់រយៈពេលមធ្យម និង វែង ពិសេស តាមរយៈការលើកកម្ពស់ផលិតភាព, កិច្ចសម្រួលពាណិជ្ជកម្ម និង ការធ្វើឱ្យប្រសើរឡើងនូវភាពងាយស្រួលក្នុងការធ្វើធុរកិច្ចនៅកម្ពុជា; ព្រមទាំងវិធានការសំដៅដោះស្រាយបញ្ហាប្រឈមជាក់ស្តែងតាមវិស័យ និង អនុវិស័យសំខាន់ៗ សម្រាប់រយៈពេលមធ្យមខាងមុខ ដូចជា វិស័យកសិកម្ម, កសិ-ឧស្សាហកម្ម, ទេសចរណ៍ និង សហគ្រាសធុនតូច និងមធ្យម ជាដើម ។

ជាទៅបញ្ចប់ ខ្ញុំសូមអំពាវនាវដល់ជនរួមជាតិ, វិនិយោគិន, ធុរជន, អាជីវករ, និង ក្មួយៗកម្មករ-និយោជិតទាំងអស់គ្នា សូមមានស្មារតីនឹងនរ, មានជំនឿទុកចិត្តលើរាជរដ្ឋាភបាល, បន្តកិច្ចការងារ និង សកម្មភាពជីវិតប្រចាំថ្ងៃជាធម្មតា, ប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ក្នុងការធ្វើធុរកិច្ច ក៏ដូចជាក្នុងការបំពេញការងារ, និង ចូលរួមអនុវត្តនូវវិធានការទាំងអស់ ដែលរាជរដ្ឋាភិបាលបានដាក់ចេញមកនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់, ស្មារតីប្រឹងប្រែងអស់ពីកម្លាំងកាយ ចិត្ត, ស្មារតីស្រឡាញ់ និង ជួយយកអាសារគ្នាក្នុងគ្រាលំបាក, ស្មារតីស្រឡាញ់ជាតិមាតុភូមិ, ស្មារតីយកឈ្នះឱ្យបានលើរាល់បញ្ហាប្រឈមទាំងឡាយចំពោះមុខ, ស្មារតីជឿជាក់ថា កម្ពុជានឹងខ្លាំងជាងពេលមុនៗ នៅពេលឆ្លងផុតពីបញ្ហាប្រឈមទាំងនេះ និង ស្មារតីជឿជាក់លើអនាគតដ៏ភ្លឺស្វាងសម្រាប់គ្រប់ជំនាន់ទៅមុខទៀត ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព ដែលយើងខិតខំសម្រេចបានមកដោយលំបាកលំបិន ជាមួយនឹងពលីកម្មដ៏ធំធេងមិនអាចកាត់ថ្លៃបាន ។

***សូមអរគុណ!***